Washington State Department of Commerce

**RENT ASSISTANCE INFORMATION**
**OCTOBER 2021**

# មានផ្តល់ជំនួយថ្លៃឈ្នួលផ្ទះក្នុងអំឡុងវិបត្តិជំងឺ COVID-19

ប្រសិនបើអ្នកហួសថ្ងៃកំណត់បង់ថ្លៃឈ្នួលផ្ទះរបស់អ្នក ឬប្រឈមហានិភ័យនឹងការបណ្តេញចេញ អ្នកមានជម្រើសបី។

- **ជំនួយថ្លៃឈ្នួលផ្ទះ។** អង្គការក្នុងតំបន់នៅទូទាំងរដ្ឋកំពុងតែជួយផ្តល់ជំនួយថ្លៃឈ្នួលផ្ទះ។ អ្នក ឬម្ចាស់ផ្ទះរបស់អ្នកអាចទាក់ទងអង្គការក្នុងតំបន់នៅក្នុងខោនធីរបស់អ្នកសម្រាប់ព័ត៌មានអំពីរបៀបដាក់ពាក្យសុំ។

  បញ្ជីឈ្មោះអ្នកផ្តល់ជំនួយថ្លៃឈ្នួលផ្ទះ៖ https://www.commerce.wa.gov/serving-communities/homelessness/eviction-rent-assistance-program/

  ប្រសិនបើអ្នកជាអ្នកជួលផ្ទះដែលមានអាយុក្រោម 25 ឆ្នាំ សូមទាក់ទងអ្នកផ្តល់កម្មវិធីជំនួយថ្លៃឈ្នួលផ្ទះសម្រាប់ករណីបណ្តេញចេញមនុស្សពេញវ័យ និងយុវជនក្នុងតំបន់។ បញ្ជីឈ្មោះ៖ https://www.commerce.wa.gov/serving-communities/homelessness/youth-and-young-adult-eviction-rent-assistance-program/

- **កម្មវិធីដំណោះស្រាយការបណ្តេញចេញ។** អ្នក ឬម្ចាស់ផ្ទះរបស់អ្នកអាចទាក់ទងមជ្ឈមណ្ឌលដំណោះស្រាយទំនាស់ក្នុងតំបន់របស់អ្នកបាននៅក្នុងខោនធីដែលអ្នករស់នៅ។ មជ្ឈមណ្ឌលទាំងនេះអាចជួយដោះស្រាយបញ្ហាទាក់ទងនឹងការបណ្តេញចេញបាន។ បញ្ជីឈ្មោះ៖ resolutionwa.org/locations

- **សិទ្ធិក្នុងការពិគ្រោះកម្មវិធីផ្លូវច្បាប់។** អ្នកជួលផ្ទះដែលទទួលបានជំនួយសាធារណៈ ឬដែលមានប្រាក់ចំណូលទាបខ្លាំង -- ប្រាក់ចំណូលប្រចាំឆ្នាំចំនួន $25,760 សម្រាប់ឯកតបុគ្គល ឬ $53,000 សម្រាប់ក្រុមគ្រួសារដែលមានគ្នាបួននាក់ – អាចធ្វើការជាមួយមេធាវីដោយឥតគិតថ្លៃបានក្នុងអំឡុងរឿងក្តីបណ្តេញចេញ។ សូមទាក់ទងខ្សែទូរសព្ទសម្រាប់ការពិនិត្យរកការការពារការបណ្តេញចេញតាមលេខ 855-657-8387 ឬដាក់ពាក្យសុំអនឡាញតាមរយៈ nwjustice.org/apply-online។

## ស្វែងយល់បន្ថែមទៀតពីសំណាក់អគ្គមេធាវីរដ្ឋ

Office of the Attorney General (ការិយាល័យអគ្គមេធាវី) កំពុងផ្តល់ព័ត៌មានផ្លូវច្បាប់ និងគោលនយោបាយបន្ថែមទៀតជាច្រើនភាសាអំពីកម្មវិធីទាំងនេះ និងបញ្ហាម្ចាស់ផ្ទះ-អ្នកជួលផ្ទះដទៃទៀតនៅលើគេហទំព័រ atg.wa.gov/landlord-tenant។

## សូមហៅទូរសព្ទទៅលេខ 2-1-1 សម្រាប់ព័ត៌មានអំពីជំនួយជាមួយនឹងការចំណាយផ្សេងទៀត

សូមចូលទៅកាន់គេហទំព័រ wa211.org ឬហៅទូរសព្ទទៅលេខ 2-1-1 ដើម្បីពិគ្រោះជាមួយនរណាម្នាក់ដែលអាចផ្តល់ព័ត៌មានដើម្បីជួយគេទូទាត់ចំណាយផ្សេងៗដូចជាថ្លៃថាមពល ម្ហូបអាហារ អ៊ីនធឺណិត និងច្រើនទៀត។